# KhmerPost USA

សុបិន : (267) 253-3947, សែម : (781) 244-0522


**មាតិការឿង** — **ទំព័រ**


១-ទិវាមាតាមានន័យអ្វីខ្លះ..........០៣
២-ព្រះគ្រូចៅអធិការ សែម សុឃឿន..........០៤
៣-កុងស៊ុលកិត្តិយសខ្មែរនៅហ្វឺឡា..........០៦
៤- វិធីបន្ធូរ-លំហែកាយ និងចិត្ត..........១៣
៥- ប្រវត្តិរណសិរ្សជាតិរំដោះ..........១៤
៦-៧ថ្ងៃនៅលើទឹកដីម៉ារ៉ុខ្យូ..........២០



VOL. 06 ISSUE 109 Jun.22th - Jul.05th, 2012


# កីឡាអូឡាំពិកក្រុងឡុនដុន មានកីឡាខ្មែរដែរ

នៅក្នុងចំណោមកីឡាករដ៏ពូកែ ដ៏ខ្លាំង ដ៏លឿន ដ៏ជំនាញប្រមាណ១០៥០០នាក់ ដែលមកប្រកួតយកជើងឯកពិភពលោក ខាងកីឡាអូឡាំពិក ក៏មានខ្មែរយ៉ាងហោចក៏៦នាក់ដែរ ដែលគេបានចំរាញ់យកអ្នកឈ្នះក្នុងចំណោមអ្នកឈ្នះនៅកម្ពុជា មកចូលរួមប្រកួតនឹងគេដែរ ។ ថ្ងៃ ២៧ កក្កដា ខាងមុខពិធីសម្ពោធ នឹងប្រារព្ធយ៉ាងខ្ទរខ្ទាំដែលប្រព័ន្ធផ្សព្វផ្សាយ និងបំពងសម្លេងព្រមទាំងបង្ហាញរូបភាព នៃវិរៈបុរ វិរៈនារី ដ៏កំពូលពិភពលោកឱ្យគេបានឃើញស្នាដៃឯកនារយៈពេល២សប្តាហ៍នៃការប្រកួតប្រជែងនាទីក្រុងនៃប្រទេសអង់គ្លេសនោះ ។

-**ទី១** ហែម ថុនពន្លឺ អាយុ ២២ ឆ្នាំ ប្រុស ចូលប្រកួតកីឡាហែលទឹក




-**ទី២** ហែម ថុនវិធីនី អាយុ ១៩ ឆ្នាំស្រី ចូលប្រកួតហែលទឹក

**តទៅទំព័រទី៨**

# ប្រេសត្ថិបខ្មែរផ្ទួស ស.រ.អា នៅរូបឹន ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២"ត"





**សូបិន** : តើប្រវត្តិនៃភ្លេងខ្មែរមានតាំងពីពេលណាមក?



**ម៉ម យឺន** : ខ្ញុំអាយុជិត ៨០ឆ្នាំហើយ តាំងពីខ្ញុំកើតមកឃើញភ្លេងពិណពាទនេះរួចជាស្រេចហើយ វាកើតមុនខ្ញុំច្រើនរយឆ្នាំទៅទៀត នៅលើជញ្ជាំងប្រាង្គប្រាសាទក៏មានជាចម្លាក់រូបភាពលើនោះ ដូចនេះគេអាចថាគ្រឿងភ្លេងនេះ កើតតាំងពីសតវត្សទី១ក៏ថាបាន...

អ៊ុំមសេរីកោហ៊ុន : ខ្ញុំចាំកាលពីធ្លាប់ស្តាប់អត្ថាធិប្បាយក្នុងវិទ្យុជាតិថា គ្រឿងភ្លេងនេះ មានកំណើតនៅខេត្តតាកែវ ពីព្រោះទីនោះជាក្រុងនៃនគរគោកធ្លក ទីដែលកកើតបានជាកម្ពុជា នៅពេលក្រោយមក គឺនៅអំឡុងឆ្នាំ៥៥១ រជ្ជកាលព្រះបាទភវវរ្ម័ន...

រាត្រីនោះក្រុមយុវសិល្បៈករខ្មែរខាងភាពយន្តបាននាំយកផលិតកម្មរបស់ខ្លួនមកបង្ហាញ-ខ្សែភាព

**តទៅទំព័រទី៥**









# បុណ្យបំបួស និងបុណ្យពុទ្ធាភិសេក

ព្រះសង្ឃធិបតី សៅឃន ធម្មត្ថេរោ ប្រធានសហគមន៍ ព្រះសង្ឃខ្មែរសហរដ្ឋអាមេរិក និងគណៈកម្មការជំនួយការបានឯកភាពគ្នារៀបចំពិធីបំបួសប្រចាំឆ្នាំដល់បរិស័ទជាគ្រហស្ថទាំងពីរភេទចំនួន១២១រូប ដែលមានសទ្ធាជ្រះថ្លា ចង់បំពេញផ្នួសជាភិក្ខុ សាមណេរី សីលវតីសីល១០ និងសីល៨ ក្នុងរយៈពេលខ្លី ( ប្រាំពីរថ្ងៃ) សូមអញ្ជើញចុះឈ្មោះចាប់តាំងពីពេលនេះតទៅ ។ ក្នុងពេលជាមួយគ្នានេះដែរ ក៏មានរៀបចំពិធីបុណ្យពុទ្ធាភិសេក ថ្វាយដល់ព្រះពុទ្ធរូបអង្គធំ ដែលទើបជាវថ្មីមកពីប្រទេសកម្ពុជា តម្កល់ទុកជាទីគោរពបូជា នៅក្នុងវត្តខ្មែរឡូវែល ក្រុងឡូវែល រដ្ឋម៉ាស្សាឈូសែត ។



អាស្រ័យហេតុដូចខាងលើនេះ សូមលោក លោកស្រី ជាពុទ្ធបរិស័ទគ្រប់វ័យគ្រប់ភេទ ដែលស្ថិតនៅគ្រប់ទិសទី ដែលមានបំណងចង់បំពេញផ្នួស ដើម្បីភ្ជាប់និស្ស័យ ក្នុងព្រះពុទ្ធសាសនា និងប្រាថ្នាចូលរួមបំពេញកុសល ក្នុងពិធីបុណ្យពុទ្ធាភិសេក សូមមេត្តាចុះឈ្មោះ និងធ្វើទំនាក់ទំនងព័ត៌មានបន្ថែម តាមអាស័យដ្ឋានដូចខាងក្រោម:

**ទីកន្លែង : វត្តខ្មែរឡូវែល** នៃរដ្ឋម៉ាស្សាឈូសែត

Vatt khmer Lowell- 48
Townsend Avenue, Lowell, MA 01854



**កាលបរិច្ឆេទ :** ពិធីបុណ្យបំបួស ចាប់ផ្តើមនៅម៉ោង ១កន្លះ រសៀលថ្ងៃសៅរ៍ ៨រោច ខែទុតិយាសាឍ

ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃទី៧ ខែ កក្កដា ឆ្នាំ ២០១២

ពិធីបិណ្យពុទ្ធាភិសេក ធ្វើនៅម៉ោង ១កន្លះ រសៀលថ្ងៃអាទិត្យ ៥រោច ខែទុតិយាសាឍ ឆ្នាំ-រោង ចត្វាស័ក

ត្រូវនឹងថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០១២

**ទំនាក់ទំនង :** អ្នកស្រី ម៉ែន ម៉ាយ៉ា ( ៩៧៨) ៥០១-០១០៦ ឬ ( ៩៧៨) ២៥១-២៥៨៧

**លោក សោម សម្បត្តិ** ( ៩៧៨) ៧២៩-៥៥៦៦

www.ckbm.org

# Summer Buddhist Academy Program

## July 7-14, 2012

### "Traditional Buddhist Ordination & Buddha Statues Abhisekkha Ceremonies"

We, the active members of the Vatt Khmer Lowell, are pleased to announce our first Summer Buddhist Academy Program, under the tutelage of **Venerable Sao Khon Dharmmathero,** Senior Abbot of Vatt Khmer Lowell and also President of Community of Khmer Buddhist Monks, Inc., to take place at 48 Townsend Avenue, Lowell, MA 01854 from July 7 to July 14, 2012.

Our first year Summer Buddhist Academy Program is to reach out and recruit **121** Cambodian American youth, both male and female, aged between 12 to 16, and also adults (male and female) who are interested in learning about Theravada Buddhism and traditional Khmer culture by becoming ordained as BHIKKHU, or Samanera, or Samaneri, or just regular Buddhist disciple during an intensive summer academy program for a short period of 7 days.

In addition to the ordination of 121 youth and disciples, the Community of Khmer Buddhist Monks will also hold a **Buddha Abhisekkha** of three new Buddha statues that have just been donated by generous supporters to the Buddhist monks to be permanently enshrined at the Vatt Khmer Lowell.

Therefore, please consider taking part in this Khmer time-honored tradition by becoming ordained as Buddhist Bhikkhu and be also the disciples of the Theravada Buddhism as stated in the above mentioned program.

**ORDINATION PROGRAM & BUDDHA STATUES ABHISEKKHA CEREMONY**

**WHERE: Vatt Khmer Lowell/Community of Khmer Buddhist Monks, Inc.**
48 Townsend Avenue; Lowell, MA 01854

**WHEN:** July 7th, 2012 starting at 1:30 pm – **Buddhist Ordination Ceremony**
July 8th, 2012; 1:30 pm - **Buddha Statues Abhisekkha Ceremony**

**CONTACT:** Ms. Maya Men at (978) 501-0106, or (978) 251-2587 (Vatt Khmer Lowell) Mr. Sambath Soum at (978) 729-5566
www.ckbm.org

# លេខទី១៧-តើទិវាមាតាមានន័យអ្វីសម្រាប់យើង?



**ដោយ : គឹម ភៀន**

ទិវាមាតាបានកន្លងផុតទៅហើយយ៉ាងស្ងៀមស្ងាត់ខ្ញុំសឹងតែពុំបានដឹងថា ថ្ងៃទី១៣ខែឧសភានេះ ជាថ្ងៃ"ទិវាមាតាទេ" កុំតែក្មួយសុបិន អញ្ជើញទៅញ៉ាំបាយល្ងាចហើយប្រាប់ថា : "អញ្ជើញអ៊ុំបាយល្ងាច ដើម្បីរីករាយថ្ងៃទិវាមាតា" ។ ខ្ញុំបានទទួលពាក្យអញ្ជើញ ដោយរីករាយនឹងដោយរំជួលចិត្តផង និងហាក់ដូចជាស្រឡាំងកាំងទៀត... ព្រោះ" ទិវាមាតា" បានចូលមកដល់រហ័សពេកខ្ញុំមិនដែលនឹកគិតដល់ទាល់តែសោះ ហើយវាជាពាក្យមួយម៉ាត់មានឥទ្ធិពលហាក់ ដូចជាស័ក្តសិទ្ធ និងមានកម្លាំងទាញយ៉ាងព្រឺព្រួច ធ្វើឱ្យចិត្តខ្ញុំនឹកដល់ម៉ែគិតដល់ម៉ែ នឹកដល់អនុស្សា វរីយ៍មួយម៉ឺនអាល័យ! ម៉ែអើយ! ម៉ែនៅឯណាកូន នឹកម៉ែ,កូនស្រឡាញ់ម៉ែណាស់ ម៉ែអើយ!...ម៉ែទៅដល់ស្ថានណា ? កូនចង់ឃើញម៉ែ ហើយបានហើយ ពាក្យយ៉ាងពិសិទ្ធិបំផុតថា"ម៉ែ!ៗ" ។

ដោយរំជួលចិត្តនឹងអាឡោះអាល័យម៉ែពេក នៅយប់នេះ ទោះបីជាទិវាមាតាបានកន្លងផុតយូរថ្ងៃទៅហើយក៏ដោយតែខ្ញុំមិនអាចធ្មេចភ្នែកបំភ្លេចរូបភាពម៉ែបានទេ ក៏ក្រោកឡើងកណ្តាលអាធ្រាត្រនាទីក្រុងហ្វីឡាដែលហៀរដែលកំពុងមានផ្គររន្ទះនិងភ្លៀងស្រិចៗទៀតផង ។ ម្នាក់ឯងក្រោមដំណក់ទឹកភ្លៀងមកលើដំបូលផ្ទះម្តងខ្លាំងម្តងស្រាលហាក់ដូចជាសន្ទុះចិត្តខ្ញុំម្តងព្រឺព្រួចឈឺផ្សាម្តងហាក់ ដូចជាសះស្បើយធូរស្រាល...ចង់ចាប់ទូរស័ព្ទហៅទៅក្មួយសុបិន ដើម្បីសំណេះសំណាលពីភាពរំជើបរំជួលព្រឺព្រួចស្រណោះអាល័យដល់ម៉ែនៃចិត្តខ្ញុំនាពេលនេះប្រាប់នាង, តែយប់ជ្រៅណាស់ទៅហើយខ្លាចរំខានដំណេកនាង។ មិនដឹងគួរធ្វើអ្វីទេ, ខ្ញុំក៏ក្បួកអង្គុយមុខកុំព្យូទ័រចាប់ផ្តើមសរសេរជូននាងហាក់ដូចជានិយាយទៅកាន់នាងដូច្នោះដែរ ។

ហ្វីឡាដែលហៀរនាអាធ្រាត្រមួយពោរពេញដោយផ្គរ រន្ទះនៃយប់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ មកក្មួយសុបិន នារាត្រីមួយដែលអ៊ុំនឹកម៉ែ !

ក្មួយសុបិនជាទីស្រឡាញ់រាប់អាន ! មិនដឹងជាឥទ្ធិពលនៃទិវាមាតាមានថាមពលដ៏ខ្លាំងយ៉ាងនេះសោះ៤យប់ ហើយដែលអ៊ុំគេងមិនលក់ស្កប់សោះតាំងតែពីយើងនាំគ្នាទៅញ៉ាំអាហារជាមួយគ្នា នារាត្រីទិវាមាតានោះមក អ៊ុំចេះតែនឹកម្តាយអ៊ុំ, ស្រមៃឃើញគាត់,ឃើញមុខដ៏ស្លូតនឹងស្ងាត់ស្ងៀមរបស់គាត់ហាក់ដូចជាផ្ទៃទឹកមឹងដែលស្ងប់ខ្យល់...សន្តិភាពផ្ទៃម្លេះទេទឹកមុខម៉ែខ្ញុំ! នេះជានិមិត្តរូបនៃមេត្តាករុណាគ្មានកោះត្រើយ ! នៃសេចក្តីស្រឡាញ់គ្មានលក្ខខ័ណ្ឌនៃក្តីលះបង់ដ៏ធំស្មើមេឃស្មើផ្កាយ ។ មានអ្វីល្អប្រសើរជាងម៉ែទៀត ? ពិតជាគ្មានសោះឡើយ ព្រោះម៉ែជាអ្វីៗទាំងអស់ ព្រោះម៉ែជាប្រភពនៃទឹកអម្រឹតមិនចេះ រីងស្ងួត, ជាប្រភពទឹកដ៏ត្រជាក់នឹងជាថ្នាំទិព្វសម្រាប់ប្រោះព្រំកូនមានទុក្ខ,ក្តៅក្រហាយឈ្លួលឆេះឱ្យមានភាពសុខដុំរមនាឡើងវិញបាន... ម៉ែអើយ! ឥឡូវនេះម៉ែនៅឯណា? កូននឹកម៉ែហើយស្រឡាញ់ម៉ែច្រើនណាស់!។

ក្មួយសុបិនជាទីរាប់អានរាត្រីនេះយើងបានជួបជុំនូវមិត្តជិតស្និទ្ធមួយចំនួន រួមមានលោកបង ម៉ម យីន និងភរិយារបស់គាត់លោក ពិន សំខុន ព្រមទាំងកុមារប៉ុនណា រ៉ូ ពិន គ្រួសារលោកវេជ្ជបណ្ឌិតដែលរួមមានគ្នាបីនាក់មកពីFloridaបន្ទាប់មកមានរូបក្មួយ សុបិន បន្ទាប់មកមានក្មួយស្រីតូចតុនស្រស់ស្អាតជាប់ឈាមជាខ្មែរក្រោមបាន បើកភ្នែកសំឡឹងជីវិតដំណើររបស់ខ្លួននៅជំរុំនាប្រទេសថៃក្នុងដំណើររបស់ម្តាយនាងស្វែងរកសន្តិភាព និងសេរីភាពនៅប្រទេសទី៣។ នាងទើបតែប្រឡងជាប់ទទួលបាននូវសញ្ញាប័ត្របរិញ្ញាថ្មីៗ នៅឯរដ្ឋកាលីឯណោះ នាងបានកាត់មករកសុបិនមិត្តពីកុមារភាពរបស់នាងដែលនាងធ្លាប់ស្រឡាញ់រាប់កាលនៅរៀនជាមួយគ្នាឯរដ្ឋកាលីហ្វ័នៀ ។ ហើយនាងបានអង្គុយក្បែរអ៊ុំគ្រាន់ស្រួលអ៊ុំសំណេះសំណាលគ្នា ។ សុបិនមានដឹងហេតុអីបានជាអ៊ុំទើបស្គាល់នាងសោះបានជាយកចិត្តទុកដាក់ចំពោះនាងខ្លាំងយ៉ាងនោះទេ? ព្រោះនាងមានចំណុចពិសេសមួយធ្វើឱ្យអ៊ុំមិនស្រឡាញ់មិនកើត! នាងបានកើតនៅជំរុំ ហើយបាននាំមករស់នៅកាលី កាលពីនៅយំង៉ាៗទារបៅដោះម្តាយនៅឡើយ នាងបានឆ្លងកាត់ការសិក្សាទទួលបរិញ្ញា-បត្រនៅស្រុកគេដែលនាងបានប្រើភាសាអង់គ្លេសតាំងពីពេលនាងចេះ ក្រង៉េក្រ ង៉ូជាមួយម្តាយម្ល៉េះ ហេតុអ្វីនាងចេះភាសាខ្មែរច្រើនគួរសមយ៉ាងនេះ? មិនគ្រាន់តែចេះភាសារខ្មែរ ប្រើការបានប៉ុណ្ណោះទេ តែថែមទាំងចូលចិត្តនិយាយភាសារខ្មែរទៀតផង ។ នេះ ជាបុគ្គលិកលក្ខណៈរបស់នាងប្លែកពីនារីខ្មែរដទៃដែលរស់នៅនៅទឹកដីនេះ ។ មិនគ្រាន់តែនិយាយភាសារខ្មែរប៉ុណ្ណោះទេ តែនាងនិយាយភាសារខ្មែរសំនៀងអ្នកព្រះត្រពាំងទៀតផង ។ អូ! កូនចៅអ្នកណាគេគួរឱ្យស្រឡាញ់ម្ល៉េះ ? ការជួបជុំគ្នានេះមានភាពស្និទ្ធស្នាលមឹងរីករាយណាស់ គួរចាត់ទុកជាអនុស្សាវរីយ៍ល្អមួយបាន ។ តែក្នុងអនុស្សាវរីយ៍ល្អនេះវាមានការខ្វះចន្លោះអ្វីមួយដែរ ដែលអ៊ុំចេះតែរង់ចាំមើលថា ក្មួយនឹងនិយាយអ្វីមួយ ឬសុំឱ្យអ៊ុំនិយាយអ្វីបន្តិចដែរពីទិវាមាតានេះ តែរង់ចាំរហូតដល់យើងសុំលាបែកគ្នាមកផ្ទះរៀងៗខ្លួនដោយគ្មានពួកគ្នាយើងណាម្នាក់បញ្ចេញវាចាមួយម៉ាត់ពីទិវាមាតានេះសោះ ។ ហេតុនេះអ៊ុំសុំយករាត្រីគេងមិនលក់នឹងពោរពេញដោយផ្គរផ្គររន្ទះសម្រាប់សំណេះសំណាលជាមួយក្មួយ និងមិត្តអ្នករាប់អានរបស់យើងពីទិវាមាតានេះទៅចុះ ។



**ទិវាមាតាមានអត្ថន័យយ៉ាងណាប្រទេសណាបង្កើតទិវានេះឡើង ហើយមានបំណងយ៉ាងដូចម្តេច ?**

មិនមែនតែជនណាម្នាក់ទេដែលស្រឡាញ់ម៉ែហើយ ក៏ពុំមែនតែប្រទេសមួយណាទេ ដែលយល់ស្របថា មាតា មានគុណមហាធ្ងន់ និងមាតាជានិមិត្តរូបនៃក្តីស្រឡាញ់, មេត្តាករុណា, សណ្តោះដោយគ្មានលក្ខខ័ណ្ឌ...ម៉ែជាព្រះនៃមនុស្សជាតិក្នុងលោក,ក្នុងចក្រវាឡ ។ មិនមែនតែមនុស្សទេ ដែលយល់ថា ម៉ែជាក្តីស្រឡាញ់តែសត្វទាំងឡាយក៏យល់យ៉ាងនោះដែរ រហូតដល់មេខ្លា មេសឹង្ហ មេឆ្កែចចក ក៏ពុំចេះ ធ្វើបាបកូនវាដ៏តិចតួចឡើយ មានតែក្តីស្រឡាញ់យ៉ាងធំធេង ។ គឺប្រទេសនៅទិសព្រះអាទិត្យរះដែលមានផ្កាសាគូរ៉ារីកស្គុះស្គាយនៅលើភ្នំហ្វូស៊ីនេះឯងហើយដែលជាប្រទេសនឹកឃើញមុនគេបង្កើតថ្ងៃ "ទីវាមាតា" ដើម្បីប្រជាជនគេរំលឹកនឹកឃើញគុណមហាធ្ងន់នៃមាតាយ៉ាងហោចណាស់ឱ្យបានម្តងដែរក្នុងមួយឆ្នាំ ។

គោលបំណងនៃការបង្កើតទីវាមាតានេះមានបំណងឱ្យកូនចៅបានយល់ដឹងពីគុណម្តាយឱ្យបានទូលមទូលាយ ។ ព្រោះបើមិនជួយគ្រើនរំលឹកទេមានមនុស្សខ្លះបណ្តោយខ្លួនមិនឱ្យខ្លួនស្គាល់យល់ពីមនោសញ្ចេតនា ពីន័យដ៏ធំធេងនៃចិត្តម្តាយចំណោះកូនឡើយ ។ រឿងនេះមិនខុសពីប្រទេសខ្លះដែលគេធ្វើបុណ្យសំរាប់រំលឹកដល់គុណបំណាច់នៃមហាក្សត្រទាំងឡាយរបស់គេ ។ ទាល់តែធ្វើយ៉ាងនេះនឹងទើបមានឱកាសឱ្យរដ្ឋាភិបាលគេថ្លែងសរសើរ,ដឹងគុណពីស្នាដៃរបស់វីរៈបុរស,ពីមហាក្សត្រទាណងឡាយរបស់គេដែលមានគុណកសាង,ការពារ,ឃុំ គ្រងទឹកដី, ប្រទេសជាតិមាតុភូមិដែលជាមរតកទុកមកឱ្យកូនចៅគេជំនាន់ក្រោយ ។ (សុំនិយាយបន្តិចពីប្រទេសខ្មែរយើងទៅចុះ...)លើពិភពលោកយើងនេះប្រហែលជាមានតែប្រទេសខ្មែរមួយទេមើលទេ ដែលមិនចេះធ្វើបុណ្យរំលឹកដល់គុណបំណាច់របស់វីរៈបុរសរបស់ខ្លួន ដល់អ្នកមានគុណបានធ្វើពលីកម្មដើម្បីកសាងនូវមរតក និងរក្សាថែទុកមកឱ្យយើងដល់សព្វថ្ងៃ

**តទៅទំព័រទី១៨**

**KHMER POST USA, LLC**
**East Coast Publication**

**Pin Samkhon,**
*Publisher & Editor-in-Chief*
Email: pinsamkhon@gmail.com
*Staff Writers:* **Loeum Im**

*Contributed Writers:*
**Mam Yin, Kim Phien**
*Advertising Department*

**Soben Pin**
KhmerPostUSA@gmail.com
**267-253-3947**

**Sam Khoeun**
*Sales Consultant*
**(781) 244-0522**

*Design Staffs:*
**Leang Heng & Mong Meng**

~~~~~

KhmerPost USA, LLC is an independent newpaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local, community, and national news; and give an insight into Cambodia & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English.
It published twice a month in Pennsylvanian & Massachusett.

~~~~

Semimonthly edition subscription is available within the U.S. & Canada at $60.00 and 70 Euros in Europe per year.
Money order or check is accepted and made payable to:
KhmerPost USA, LLC
438 LINDLEY AVE.
Philadelphia, PA 19120

~~~

The Khmer Post has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009
~~~

# ព្រះគ្រូចៅអធិការ សែម សុឃឿន ថាវត្ត“ដីហុយ” គ្មានកាកសំណល់ជាតិពុលដូចពាក្យចចាមអារាមទេ

**ដោយ : អ៊ុម លឿម**

"វត្តដីហុយ"ជារហ័សនាមនៃវត្តមួយក្នុងចំណោមអារាម ព្រះពុទ្ធសាសនារបស់ខ្មែរ ទាំងបួនក្នុងទីក្រុងហ្វីឡាដែលហ្វៀ ។ បើគេនិយាយដល់ឈ្មោះ "វត្តដីហុយ" នេះអ្នកផង ទាំងពួងដែលជាពលរដ្ឋខ្មែរក្នុងសហគមន៍ហ្វីឡាដែលហ្វៀភាគច្រើនប្រាកដជាស្គាល់យ៉ាងច្បាស់អំពីទីកន្លែងនៃអារាមព្រះពុទ្ធសាសនាមួយនេះ ព្រោះដោយហេតុទីនោះ ជាទីកន្លែងដែលធ្លាប់មានការប្រារព្ធនូវសាសនៈពិធីជាហូហែ ជាពិសេសគឺតែងមានការប្រគំតន្ត្រី និងមានការរាំលេងកំសាន្តក្នុងទ្រង់ទ្រាយធំនៅពេលមានពិធីបុណ្យទានម្តងៗ ។



ជាមួយនឹងផ្ទៃដីធំល្វឹងល្វើយដែលមានទំហំប្រមាណជា៩ហិកតាកន្លះ ឬប្រមាណជាពីរហិកតាកន្លះនោះ "វត្តដីហុយ"ហាក់នៅពុំមានសមិទ្ធផលជាដុំកំភួននៅឡើយទេ ។ ប៉ុន្តែផ្ទុយទៅវិញវត្តខ្មែរមួយនេះ ត្រូវបានល្បីឈ្មោះបោះសំឡេងមិនតិចប៉ុន្មានឡើយដល់សហគមន៍ខ្មែរ នាទីក្រុងហ្វីឡាដែលហ្វៀ និងដល់បណ្តារដ្ឋជិតខាងមួយចំនួន ។ តាមពិតប្រភពនៃឈ្មោះ"វត្តដីហុយ"នេះត្រូវបានមនុស្សមួយចំនួននិយាយក្នុងការលេងសើចប៉ុណ្ណោះ ព្រោះដោយសារធ្លាប់មានដីហុយនៅពេលមានកម្មវិធីបុណ្យ ឬកម្មវិធីរាំរែកកំសាន្តម្តងៗ ។ រីឯឈ្មោះពិតរបស់វត្ត គឺ"វត្តខ្មែរបាលិលេយ្យ" ។

យោងតាមសង្ឃដីការរបស់ព្រះគ្រូចៅអធិការវត្តបញ្ញាទីបោ សែម សុឃឿន ដែលបានផ្តល់កិច្ចសម្ភាសន៍ជាមួយ"ខ្មែរផុស"កាលពីថ្ងៃអាទិត្យទី១៧ ខែមិថុនា កន្លងមកនេះ បានឱ្យដឹងថា ក្នុងចំណោមវត្តទាំងអស់ក្នុងទីក្រុងហ្វីឡាដែលហ្វៀ គឺមានតែវត្ត"បាលិលេយ្យ"ទេ ដែលកើតមុនគេ និងមានតែមួយប៉ុណ្ណោះ កាលពីដំបូងហើយវត្តនេះ បានចាប់បដិសន្ធិតាំងពីឆ្នាំ១៩៨៧មកម្លេះ ។ បច្ចុប្បន្នវត្ត "បាលិល័យ" មានទីតាំងនៅ២៤០ Greenwich St,Philadelphia Pa 19145 នាតំបន់ហ្វីឡាដែលហ្វៀខាងត្បូង ។

រហូតមកដល់ពេលនេះ "វត្តខ្មែរបាលិលេយ្យ"បានជាវដីមួយកន្លែងដ៏ធំដែលស្ថិតនៅមិនឆ្ងាយពីទីក្រុងហ្វីឡាដែលហ្វៀប៉ុន្មានឡើយ ពោលគឺស្ថិតនៅលើអសយដ្ឋាន២៧ ១០ South 58 Th street Philadelphia PA 19143 ឬអាចនិយាយបានថាស្ថិតនៅលើផ្លូវលេខ៥៨ ។

ទីនោះហើយដែលអ្នកផងទាំងពួងតែងតែហៅថា"វត្តដីហុយ" ហើយវត្តដីហុយនេះ ក៏ធ្លាប់បានធ្លាក់ជាចំណាប់ខ្មាំងនៃព័ត៌មានរអេចរអូចពីមជ្ឈដ្ឋានមហាជនខ្មែរក្នុងសហគមន៍ហ្វីឡាដែលហ្វៀយ៉ាងក្រាសក្រែ ។

ដំណឹងចចាមអារាមរបស់វត្ត"ដីហុយ"នេះ គឺគ្មានអ្វីក្រៅពីការនិយាយតៗគ្នាថា "នៅក្រោមដីនៃបរិវេណនោះ មានកាកសំណល់ជាតិពុល" ដែលជាហេតុធ្វើឱ្យខាងវត្តធ្លាក់ការត្រួតពិនិត្យ( ធ្លាក់Inspeation) និងមិនអាចសាងសង់អ្វីនៅលើដីនោះបានឡើយ ។

ទាក់ទិនទៅនឹងពាក្យចចាមអារាមអកុសលនេះ "ខ្មែរផុស"បានទទួលនូវការអនុញ្ញាតិផ្តល់នូវកិច្ច

**តទៅទំព័រទី ០៦**








តមកពីទំព័រទី ១

# ប្រេសក្លិប ខ្មែរផូស ស.រ.អា...

យន្តរឿង "Amoment in time" បានត្រូវផលិតស្រង់មកបង្ហាញជាមួយនឹងតួសម្តែងប្រាំរូប ក៏មកបង្ហាញខ្លួនពេលនោះដែរ -ផលិតកម្មដែលមានឈ្មោះថា "978 Film Production" បានបង្ហាញតួសម្តែងឈ្មោះ តុលា សុខ -មេលីសា អ៊ុក -វ៉ាកសាន កែវ -នឹង ថេត វិបុត្រសោម -

**ធី យ៉ាន :** ខ្ញុំនឹងវ៉ាស្នា គង់ នាំគ្នាបង្កើតផលិតកម្ម



នេះ សម្រាប់បង្ហាញស្នាដៃសិល្បៈ កូនខ្មែរដឹកនាំដោយក្រុមផលិតកម្មមួយទៀតនៅញូវយ៉ក ។ កុននេះថតចប់ហើយ ហើយកំពុងកាត់តយើងធ្វើនេះ ព្រោះចង់បង្ហាញហូលីវូដថា យើងនៅឡូវែលក៏មានអ្នកធ្វើកុនមួយដែរ ។

**វ៉ាស្នា នួន :** (សមាជិកគណៈក្រុមប្រឹក្សាសាលាក្រុងឡូវែល) ខ្ញុំមានសេចក្តីរីករាយណាស់ ដោយបានឃើញមនុស្សសំខាន់យ៉ាងច្រើនមករួមប្រជុំនៅប្រេសក្លិបនេះ ហើយខ្ញុំសូមអរគុណបង ពិន សំខុន និងភរិយាដែលបានខិតខំ នារយៈពេល



ពីរឆ្នាំមកហើយធ្វើកាសែតដែលយើងកាន់នៅដៃនៅឡូវែលទទួលព័ត៌មានថ្មីៗសម្បូរដោយចំណេះនឹងស្មារតីឯករាជ្យដែលគេរកមិនបាននៅទីផ្សេងទៀត ។ ខ្ញុំដឹងហើយថា គេប្រកបមុខរបរមួយសម្រាប់ឱ្យទៅជាអ្នកមានបងសំខុន នឹងភរិយាគាត់ពុំទាន់មាននៅឡើយទេ ដូច្នេះហើយខ្ញុំសូមឱ្យអ្នកទាំងអស់គ្នាជួយជ្រោមជ្រែងកាសែតនេះឡើង ហើយខ្ញុំនឹងធ្វើអ្វីគ្រប់យ៉ាង ដើម្បីកាសែតនេះរស់រានមានជីវិតវែងឆ្ងាយបាន... ខ្ញុំមានមោទនភាពនឹងកាន់កាសែតខ្មែរផូសនេះអាចហើយខ្ញុំសូមជម្រាបថា ខ្ញុំមានកិត្តិយសណាស់ដែលបានទទួលសេចក្តីអញ្ជើញមកចូលរួមក្នុងកម្មវិធីប្រេសក្លិបនេះរៀបចំជូនតំបន់របស់យើង ។

**លោក វ៉ាស្នា នួន** បានទទួលប័ណ្ណកោតសរសើរ



ពីសារព័ត៌មានខ្មែរផូស នារាត្រីប្រេសក្លិបនោះ ដោយសារសកម្មភាពរបស់លោកបានលើកដំកើងកិត្តិយស និងកេរ្តិ៍ឈ្មោះសហគមន៍ខ្មែរ បានប្រសើរជាងគេនៅតំបន់នៃឆ្នេរខាងកើតស.រ.អា ដែលសម្បូរប្រជាពលរដ្ឋខ្មែររស់នៅច្រើនបំផុត ។

**បណ្ឌិត លក្ខិណា នូ :** (សាស្ត្រាចារ្យនៅសាកលវិទ្យាល័យឡូងប៊ិច)



ខ្ញុំមាន សេចក្តីរំភើបនឹងបានមកជួបជុំគ្នានាថ្ងៃនេះ ហើយមានមុខមនុស្សមួយចំនួនដែរ ដែលខ្ញុំធ្លាប់ស្គាល់តាំងពីពេលមកធ្វើការសិក្សាស្រាវជ្រាវពីសង្គមខ្មែរ ។ ខ្ញុំបានធ្វើការជាច្រើនសម្រាប់សង្គមខ្មែរ ហើយស្វែងរកចម្លើយអំពីថា តើហេតុអ្វីបានជាខ្មែរ ចេះតែបែកបាក់គ្នា? ខ្ញុំបានទទួលចម្លើយ ពីការស្រាវជ្រាវនោះថា ខ្មែរមានជម្ងឺគិតច្រើនមិនសូវមានទំនុកចិត្តលើខ្លួនឯង គ្មានជំនឿលើអ្នកដទៃ -ខ្ញុំបានឃើញខ្មែរជាច្រើនចេញមកពីភ្នក់ភ្លើងសង្គ្រាមនាំយកមកទាំងទុក្ខសោកវេទនា ជាប់នឹងខ្លួនជាមួយគ្រួសារ ហើយពុំមានឱកាសណាមួយទេសម្រាប់ព្យាបាលជម្ងឺផ្លូវចិត្តរបស់ខ្លួនទេ ។ ដោយសារតែនៅកម្ពុជា ឯណោះមានបង្កើតតុលាការអន្តរជាតិខ្ញុំក៏គិតថា នេះជាឱកាសដ៏ប្រសើរបំផុតក្នុងការផ្តល់យុត្តិធមិឱ្យអ្នករងគ្រោះ ដោយការប្រព្រឹត្តមិនគប្បីពីសំណាក់ក្រុមខ្មែរក្រហម ពីព្រោះនេះក៏ជាវិធីព្យាបាលយ៉ាងសាកសិទ្ធដែរ យើងបានជួយឱ្យបណ្តាញពលរដ្ឋខ្មែរ ដាក់ពាក្យបណ្តឹងចំពោះឃាតករទាំងនោះទៅតុលាការឯករាជ្យ ដ៏គួរឱ្យជឿបាននោះ ពាក្យបណ្តឹងរបស់បណ្តាពលរដ្ឋខ្មែរ នៅឯបរទេសបានត្រូវតុលាការអន្តរជាតិទទួលបាន ១០០%...

**ខេវិន អ៊ី, ខហ្សលីន :** (ប្រធានគណៈកម្មាធិការនាយកសមាគមខ្មែរ)



ខ្ញុំមិនដឹងថា នេះជាចៃដន្យ ឬការរៀបចំទុកជាមុននោះទេ តែពេលនេះមានប្រធានសមាគមខ្មែរដល់ទៅបីជំនាន់ចូលរួម គឺលោក សំខាន់ ឃឿន លោក វង់ រ៉ស នឹងប្រធានប្រតិបត្តិបច្ចុប្បន្ន លោក រ៉ាស៊ី អាន -ដែល ខ្ញុំមានសេចក្តីរីករាយនឹងជម្រាបថា សមាគមខ្មែរធ្វើការបើកចំហរយ៉ាងទូលំទូលាយទៅរកសហគមន៍ទាំងអស់គ្នា...

**វង់ រ៉ស** (នាយកប្រតិបត្តិអង្គការថែទាំមនុស្សចាស់ នៅឡូវែល)



គួររំលឹកដែរថា មនុស្សចាស់ៗ យើងជាមនុស្សដ៏អស្ចារ្យ ដែលបានឆ្លងកាត់ភ្លើងសង្គ្រាមឆ្លងកាត់យន្តការអន្តោប្រវេសន៍ មកដល់នេះជួយបង្ហាត់បង្ហាញយើងឱ្យទៅមុខបាន ។ ពួកគាត់បានបរិច្ចាកអ្វីទាំងអស់អ្វី ដែលគាត់មាន ដើម្បីមកឱ្យដល់ទីនេះ -អរគុណដល់អ្នកទាំងអស់នៅទីនេះ ដែលបានដឹកនាំជួយគាំទ្រដល់ពួកគាត់ឱ្យបានចប់ដល់ចុង -

**សំខាន់ ឃឿន នឹង ម៉ាយ៉ាមែន** (តំណាងវត្តខ្មែរនៅឡូវែល)



ខ្ញុំ សំខាន់ ឃឿន សូមនាំមកជូននូវគម្រោងសង់មជ្ឈមណ្ឌលវប្បធម៌ខ្មែរ ដ៏ធំមួយដែលត្រូវការសមាជិក ៨៤ម៉ឺននាក់ មកឧបត្ថម្ភថវិកាចំនួន១០លានដុល្លារ ដែលយើងចាប់ផ្តើមតាំងពីឱកាសចូលឆ្នាំខ្មែរ កន្លងទៅនេះមកម្ល៉េះ ។ គឺសមាជិកម្នាក់ចូលចាប់កុសលជាវព្រះពុទ្ធរូបតម្លៃ១០០ដុល្លារ រួចហើយគេឆ្លាក់ឈ្មោះអ្នកជាវនៅលើព្រះពុទ្ធរូបនោះហើយ យកតម្កល់ក្នុងព្រះវិហារដែលនឹងត្រូវសង់ឡើងនាពេលខាងមុខ ។ យើងយកមកជាមួយនូវខិត្តប័ណ្ណមានកម្មវិធីដែលយើងបានបោះពុម្ពយកមកចែកជូន ដើម្បីឱ្យលោកអ្នកអាចមើលឃើញនឹងយល់អំពីគម្រោងដ៏ធំធេងនេះ ធ្វើឡើងសំរាប់សហគមន៍ខ្មែរយើង ។ ខ្ញុំសូមអញ្ជើញអស់លោកអ្នកគ្រប់គ្នា មកចូលរួមជាសមាជិក ហើយដើម្បីជាការអរគុណឈ្មោះលោកអ្នកនឹងបានត្រូវឆ្លាក់ជាអចិន្ត្រៃយ៍នៅលើព្រះពុទ្ធរូបដែលត្រូវតម្កល់រាប់ឆ្នាំទៅមុខទៀតនោះ ។

ខ្ញុំ (ម៉ាយ៉ាមែន) សូមថ្លែងអំណរគុណដល់ខ្មែរផូសដែលបានអនុញ្ញាតឱ្យយើងខ្ញុំតំណាងវត្តខ្មែរនៅឡូវែលមកថ្លែងបង្ហាញពីសារៈសំខាន់នឹងផលប្រយោជន៍នៃវត្តខ្មែរនៅឡូវែល ដែលសាងសង់ជាបីជាន់ នៅលើដី ១២ អេគើ -នៅទីនោះយើងមានមណ្ឌលវប្បធម៌ មានវត្តមានបណ្ណាល័យ ហើយដែលយើងចំណាយលុយច្រើនពីព្រោះយើងចង់បង្ហាញនូវអ្វីជាវប្បធម៌ខ្មែរ អ្វីជាសាសនាខ្មែរ អ្វីជាព្រលឹងខ្មែរ ។ យើងចង់បង្ហាញថាខ្មែរយើងមានអ្នកតស៊ូសម្រាប់ជាតិ ក៏មានអ្នកតស៊ូសម្រាប់សាសនាដែរ... យើងបានទិញដីតម្លៃ១.២៥លានដុល្លារ ហើយយើងធ្វើការរៃអង្គាសចំនួន៥ដង



បានប្រាក់៣០ម៉ឺនដុល្លារ ហើយ... ដើម្បីមកសាងសង់នៅលើដីដែលស្ថិតនៅតាមដងទន្លេមេរីម៉ាកនេះ ។

**អ្នកស្រី អ៊ឹង ឮ :** ខ្ញុំសូមឱ្យបងប្អូនជួយគាំទ្រដល់សកម្មភាព "វិញ្ញចែកទាន" ដែលទៅដល់ជនបទយកអំណោយទៅចែកដល់ជនក្រីក្រដែលយើង ។ យើងនឹង ធ្វើការរៃអង្គាសម្តងទៀត នៅវត្តពន្លឺពុធចក្រ ថ្ងៃទី៧ កក្កដា ឆ្នាំ២០១២ សូមបងប្អូនជួយគាំទ្រផង ៕

នៅមានតលេខក្រោយ


## សិក្ខាសាលាស្តីពីការទិញផ្ទះលើកទី១
## First Time Home Buyer Workshops



សូមអញ្ជើញចូលរួមជាមួយយើង ដើម្បីរៀបចំខ្លួនទិញផ្ទះទី១របស់លោកអ្នកឲ្យបានពីរដងក្នុង១ខែ នាឆ្នាំ២០១២ នេះ យើងនឹងបង្រៀនលោកអ្នកមួយជំហានម្តងៗរៀបចំឲ្យចេញពីBad Credit ឬគ្មាន Credit ទៅរកថវិការទៅសំណើរសុំខ្ចីប្រាក់ទិញផ្ទះនឹងទៅរកសោនៃផ្ទះរបស់លោកអ្នកបានសេវាយើងនេះមិនមានយកកំរៃនិយាយភាសាខ្មែរ ហើយគ្មានចេញថ្លៃអ្វីទាំងអស់ បើលោកអ្នកមានបញ្ហាត្រូវគេរឹបអូសយកផ្ទះយើងក៏អាចជួយបានដែរ -សូមអញ្ជើញទូរស័ព្ទរកដេវីដ អ៊ូ សេង ថ្ងៃនេះ បើចង់ដឹងព័ត៌មានពីការទិញផ្ទះនេះ បន្ថែម ឬក៏ចង់ដឹងថា តើ យូណាយតិក អាចជួយលោកអ្នកបានប៉ុណ្ណា? គឺទូរស័ព្ទ 215-467-8700 x219

សូមអញ្ជើញចុះឈ្មោះថ្ងៃនេះ ដើម្បីចូលសិក្ខាសាលាតាមថ្ងៃខែដូចតទៅ:

ថ្ងៃអង្គារ ២៩ ឧសភា ២០១២ពីម៉ោង ៥:៣០ដល់៩:៣០ ល្ងាច

ថ្ងៃព្រហស្បតិ៍ ៣១ ឧសភា ២០១២ ពីម៉ោង ៥:៣០ ដល់៩:៣០ល្ងាច

ថ្ងៃអង្គារ ០៥ មិថុនា ២០១២ ពីម៉ោង ៥:៣០ ដល់ ៩:៣០ ល្ងាច

ថ្ងៃព្រហស្បតិ៍ ០៧ មិថុនា ២០១២ ពីម៉ោង ៥:៣០ដល់៩:៣០ល្ងាច

ថ្ងៃអង្គារ ១២មិថុនា ២០១២ ពីម៉ោង ៥:៣០ ដល់៩:៣០ល្ងាច

ព័ត៌មានបន្ថែមស្តីពីសិក្ខាសាលាសូមអញ្ជើញទូរស័ព្ទទៅ 215-467-8700

United Communities of Southeast Philadelphia

2029 s. 8 TH Street.
(8th & Snyder Ave)
Philadelphia, PA 19148

Tel. 215 -467-8700 ext. 220
Fax: 215 -467-1042
www.ucsep.org

United Communities Southeast Philadelphia

# កុងស៊ុលកិត្តិយសខ្មែរនៅហ្វីឡា សុំទោសចំពោះកំហុសរបស់ខ្លួន

**ដោយៈ អ៊ុំ ឈឿម**

បន្ទាប់ពីការបែកធ្លាយនៃការស្រង់ឈ្មោះរបស់សាខាគណបក្សប្រឆាំងចំនួនពីរ គឺ -គណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី ពីសំណាក់កុងស៊ុលកិត្តិយសប្រចាំទីក្រុងហ្វីឡាដែលហៀរូចមក ទើបញ៉ាំងឱ្យមានប្រតិកម្មយ៉ាងខ្លាំងពីសំណាក់សាខាបក្សប្រឆាំងទាំងពីរ ជាពិសេសភាពប្រតិកម្មនោះ គឺផ្តើមចេញពីសាខាបក្សសិទ្ធិមនុស្សតែម្តង, ហើយទីបំផុតក៏ឈានដល់ការសម្របសម្រួលបញ្ចប់នូវភាពមន្ទិលនានាដែលបានកើតឡើងចំពោះសាខាគណបក្សប្រឆាំងទាំងពីរ។

នៅក្នុងលិខិតជាភាសាអង់គ្លេសមួយចុះថ្ងៃទី៤ ខែ មិថុនា ឆ្នាំ២០១២ លោក គីម សុភ័ក្រ អនុប្រធានកុងស៊ុលកិត្តិយសប្រចាំទីក្រុងហ្វីឡាដែលហៀបានចេញសេចក្តីប្រកាសរបស់ខ្លួនថា បុគ្គលដែលលោកបានស្រង់ឈ្មោះដាក់ក្នុងកំណត់ហេតុផ្ទាល់ខ្លួនទាំងប៉ុន្មាននោះ គឺពិតជាពុំបានរាយការណ៍ដាក់ក្នុងបញ្ជីរខ្មៅរបស់រដ្ឋាភិបាល ឬក៏បង្កនូវគ្រោះថ្នាក់អ្វីមួយដល់ពួកគេឡើយ។

ជាមួយគ្នានេះលោក សុភ័ក្រ បានសុំទោសដល់ក្រុមអ្នកជាប់ពាក់ព័ន្ធចំពោះកំហុសខុសឆ្គងទាំងប៉ុន្មានដែលលោកធ្វើឱ្យមានការភ្លាំងភ្លាត់ដោយអចេតនា។

គួររំលឹកផងដែរថា ជាលើកដំបូងបំផុតក្នុងប្រវត្តិសាស្ត្រខ្មែរ នាសហគមន៍ហ្វីឡាដែលហៀដែលមានសាខាគណបក្សប្រជាជនកម្ពុជា, សាខាគណបក្សសិទ្ធិមនុស្ស ,សាខាគណបក្សសម រង្ស៊ី ,កុងស៊ុលកិត្តិយសប្រចាំទីក្រុងមួយនេះបានបង្កើតឱ្យមានជំនួបតុមូលប្រយោជន៍ស្វែងរកនូវយន្តការនៃការដោះស្រាយនូវភាពសៅហ្មងរវាងក្រុមនីមួយៗ ហើយទីបំផុតយន្តការនោះ ត្រូវបានដោះស្រាយ និងបញ្ចប់ដោយសន្តិវិធី៕

June 4th 2012

To those people whose name on my personal note:

I (Kim Sopheak) would like to assure all of you whose name I jotted down on my personal note which I intend to use for my own information that your name was not report to the government's black list nor it put you in jeopardize.

I would like to apologize for the confusion or any inconvenience this may course.

If you have any question regarding this above matter, please feel free to contact me at your convenience at the below phone number.

Sincerely,

Sopheak Kim

Sopheak Kim
(Assistance Honorable Consul)
267-588-4503
Philadelphia, Pennsylvania

# លិខិតកោតសរសើរខ្មែរប៉ុស្តិ៍ពីរអភិបាលរដ្ឋ

The Commonwealth of Massachusetts

The House of Representatives

Be it hereby known to all that:
The Massachusetts House of Representatives
offers its sincerest congratulations to:
ROGER SAMKHON PIN
~ EDITOR-IN-CHIEF OF KHMER POST USA ~

in recognition of
YOUR DEDICATION IN PROVIDING THE KHMER POST USA NEWSPAPER
IN KHAMER-ENGLISH TO THE CAMBODIAN COMMUNITIES IN MASSACHUSETTS
SINCE THE SUMMER OF 2010

The entire membership extends its very best wishes
and expresses the hope for future good fortune
and continued success in all endeavors.

Given this 5TH day of MAY, 2012
At the State House, Boston, Massachusetts

COMMONWEALTH OF MASSACHUSETTS

by: Robert A. DeLeo
Robert A. DeLeo
Speaker of the House

Offered by: 
State Representative
THOMAS A. GOLDEN, JR.

## តមកទំព័រទី ៤ ព្រះគ្រូចៅអធិការ សែម សុឃឿន ថា វត្ត...

សម្ភាសន៍ពីព្រះគ្រូចៅអធិការវត្តព្រះនាម សែម សុឃឿន ជុំវិញរាល់ពាក្យចចាមអារាមដែលតែងតែលេចឮជាហូរហែរដូចអ្វីដែល "ខ្មែរផុស"លើកឡើងពេលនេះ,ដោយព្រះគ្រូសម្តែងនូវប្រតិកម្ម និងច្រានចោលទាំងស្រុងចំពោះរាល់ពាក្យចចាមអារាមទាំងនោះ ។ព្រះគ្រូចៅអធិការមានសង្ឃដីការថា នៅស្រុកនេះ រាល់អ្វីៗទាំងអស់ គឺអាស្រ័យនៅលើច្បាប់ ដូច្នេះមុននឹងបោះទីតាំងនៅសម្បែងនេះ គឺគេមិនត្រឹមតែពិនិត្យនៅលើដី ប៉ុណ្ណោះទេ សូម្បីតែក្នុងដីក៏គេធ្វើដែរ,ហើយគេបានជីករណ្តៅជាច្រើនរណ្តៅ ដើម្បីត្រួតមើលខ្លាចមានសារជាតិពុល...។

ព្រះគ្រូ សែម សុឃឿន សង្កត់ធ្ងន់ថា: នៅបរិវេណ"វត្តដីហុយ"នេះ គឺគ្មានជាតិពុលដូចពាក្យចចាមអារាមដែលធ្លាប់បានលេចឮជាហូរហែរនោះឡើយ ។ ហើយបើយោងតាមឯកសារមួយដែល "ខ្មែរផុស"បានស្រាវជ្រាវឃើញនៅលើគេហទំព័រដែលបានបង្ហាញថា វត្តនេះត្រូវបានសាលាក្រុងហ្វីឡាដែលហៀសម្រេចឱ្យកសាងវត្តដោយស្របច្បាប់ ។ ដោយច្បាប់នោះត្រូវបានអនុញ្ញាតិ កាលពីថ្ងៃទី១១ខែសីហា ឆ្នាំ២០១០ ។

ជាមួយនឹងសំណួមពរដែល"ខ្មែរផុស"សួរថា តើពេលណានឹងមានការសាងសង់អារាមសាសនានៅទីនេះ"។ ព្រះគ្រូចៅអធិការមានសង្ឃដីការថា: ការសាងសង់ពេលណាក៏បានដែរ . តែអាស្រ័យលើថវិកា, ប៉ុន្តែយើងនឹងមានការសាងសង់បន្ទប់ទឹក (បង្គន់) ប្រុស-ស្រីជាមុនសិន ហើយនៅពេលមានថវិកានឹងមានការកសាងសាលា...។ ព្រះគ្រូបន្ថែមថា : យើងនឹងដាក់គម្រោងធ្វើវិហារកសាងសាលាចេតិយ៍ជាច្រើន លុះដល់គេវិភាគមើលទៅគេក៏យល់ព្រមទាំងអស់ ប៉ុន្តែយើងនឹងធ្វើមួយកំណាក់កាលម្តងៗ។

**សូមជម្រាបផងដែរថា :** នៅថ្ងៃទី២០-២១ខែកក្កដា ខាងមុខនេះ វត្ត"បាលិលេយ្យ"នឹងមានប្រារព្ធពិធីបុណ្យបញ្ចុះសីមា៕

**Accepting New Clients**
សូមស្វាគមន៍ដល់ភ្ញៀវគ្រប់ប្រភេទ
Immigration • Divore • Auto Crash
អន្តោប្រវេសន៍ គ្រោះថ្នាក់រថយន្ត លែងលះប្តីប្រពន្ធ
Law Office of Thomas Stylianos Jr. • 287 Appleton St. Lowell MA 01852
ការិយាល័យ មេធាវី ថូម៉ាស ស្តាលីយ៉ាណូស
Call: Narong, Sophea or Thomas សូមទូរស័ព្ទមក: ណារ៉ុង, សោភា, ឬថូម៉ាស
978-459-5000 or 800-308-3766
Only Licensed in Massachusets

300+ Cars a week

# បើកកម្មវិធីដេញថ្លៃឡានជាសាធារណៈ:

**INTERSTATE Auto Auction** Auctioncar.net (603) 893-7777

## In Salem, NH-Just 20 Minutes from Lowell MA

**OPEN TO THE PUBLIC LIVE CAR AUCTION** **Saturdays 10AM**

***Test Starts/Preview! Starts at 9AM***

## Wednesdays 5:30PM

***Free Test Drives Before You Buy!***

**Starts Wednesday at 9AM-5PM**

Only 40 Minutes From Lynn and Revere, MA
Just Over 1 Hour from Providence, RI
Or You Can Even Bid Online From Philadelphia, PA or New Jersey and Have The Car Delivered to Your Home"

**www.interstateautoauction.com**

**NH Lic#Auctioneer Alan Chambers/20 Hampshire Road - Salem NH 03079**


1997 Nissan Maxima (black), Estimated Final Bid $1,200 Sunroof


1997 Nissan Maxima, Estimated Final Bid $1,500 Automatic


2000 Mazda 626, Estimated Final Bid $1,440


2001 Isuzu Trooper, Estimated Final Bid $2,400 Limited Edition


2001 Kia Sportage, Estimated Final Bid $1650 4x4


2003 Toyota 4Runner, Estimated Final Bid $4,500 Limited Edition


2008 Honda Civic, Estimated Final Bid $9,600

-ឥតមានកក់លុយ សម្រាប់ដេញថ្លៃនៅក្នុង Online ឬទៅកន្លែងទេ -មានឡាន៣០០ ក្នុងមួយសប្តាហ៍
-Interstate Auto Auction, Salem NH ដែលនៅចម្ងាយ២០នាទីពីក្រុងឡូវែល អ្នកណាក៏អាចចូលរួមបានដែរ !
-**នៅថ្ងៃសៅរ៍ ម៉ោង១០:០០ព្រឹក** លោកអ្នកអាចបញ្ឆេះឡាន/ការសម្តែងឡានមុនម៉ោង៩ព្រឹក
-**ថ្ងៃពុធនៅវេលាម៉ោង៥:៣០នាទីល្ងាច** : លោកអ្នកអាចបើកឡានសាកល្បងពីរម៉ោង៩ព្រឹកដល់ម៉ោង៥ល្ងាច

តមកពីទំព័រទី ១

# កីឡាអូឡាំពិកក្រុងឡុន...



-ទី៣ ចៅ សុធារ៉ា អាយុ ២៧ ឆ្នាំ ស្រី ចូលប្រកួតកីឡាចម្បាប់



-ទី៤ ចាន់ សីហា អាយុ ១៨ឆ្នាំ ស្រី ចូលប្រកួតខាងរត់ប្រណាំង



-ទី៥ សួន ដារិន អាយុ ២០ឆ្នាំ ស្រី ប្រកួតកីឡាតេក្វាន់ដូ ធ្លាប់ប្រកួតនៅ Asean Game នៅថៃ នៅឡាវ ចិន ឥណ្ឌូនេស៊ី



-ទី៦ មាក ស្ទួ ចំរើន យូរី អាយុ ១៦ ឆ្នាំ ប្រុស ប្រកួតកីឡាហែលទឹក



-ទី៧ ស ជួបវ៉ាស្នា អាយុ ៣២ ឆ្នាំ ប្រុស រត់ប្រណាំង ១០០ម៉ែត្រ ធ្លាប់ប្រកួតអន្តរជាតិនៅចិន ឡាវ



១០០-២០០ម៉ែត្រ អ្នកទាំង៤នេះ សុទ្ធសឹងតែធ្លាប់ចេញទៅប្រកួតជាមួយនឹងកីឡាករបរទេសច្រើនលើកច្រើនសារ បើទោះជាខ្លួននៅវ័យក្មេងក៏ដោយក្តីតែការខិតខំប្រឹងប្រែងរបស់យុវកីឡាករខ្មែរ ក៏បានរំកិលយកការរីកចំរើនមួយកំរិតម្តងៗដែរ ។

ការឃើញយ៉ាងពុំមានកីឡាការិនីឱ្យបានច្រើន និងទទួលមេដាយមាស ឬប្រាក់ទាំងគំនរនឹងគេនោះ ក៏ព្រោះតែប្រទេសកម្ពុជា រវល់តែធ្វើសង្គ្រាម ដឹកនាំដោយអ្នកនយោបាយចំណេះតូចទាប ចិត្តចង្អៀតចង្អល់ បានធ្វើឱ្យមនុស្សឆ្នើមនឹងពូកែរបស់ខ្មែរស្លាប់បាត់បង់ជីវិតអស់ច្រើនឥតគណនា ។

បើទោះជាមានកីឡាករពូកែតិចតួចក្តី ក៏ចំនួននេះជាមោទនភាពរបស់ខ្មែរមួយដែរ យើងរីករាយនឹងឮគេហៅកីឡាករទាំងនោះ "វីរៈបុរស ឬនារីអូឡាំពិករបស់ខ្ញុំ" ដ៏គួរឱ្យរំភើបក្នុងចិត្ត ។

សូមឱ្យ "វីរៈនារី វីរៈបុរស អូឡាំពិករបស់យើង" ទទួលនូវការកោតសរសើរ និងទទួលជោកជ័យឱ្យបានត្រចះត្រចង់ ៕

**ខ្មែរប៉ុស្តិ៍**


**PEAK** Being Your Childs Best Advocate

## Cambodian Family Services Association

**បុណ្យចំរើនកុសលគ្រួសារខ្មែរ**

សូមអញ្ជើញ ពុទ្ធបរិស័ទ សមាជិក នឹងគណកម្មាធិការ "សមាគមគាំទ្រគ្រួសារខ្មែរ"
មកចូលរួមក្នុងកម្មវិធីបុណ្យចំរើនកុសលគ្រួសារខ្មែរ ដែលបានប្រព្រឹត្តទៅនៅ:

**ថ្ងៃទី** ថ្ងៃសៅរ៍ ទី៣០ មិថុនា ឆ្នាំ២០១២
**ម៉ោង** ៩ដល់ ៣ល្ងាច
**ទីកន្លែង** វត្តព្រះពុទ្ធប្រទានពរ ១៧៣២ Mifflin St
Philadelphia, PA 19145

**ចំណង** ក្រុមគាំទ្រគ្រួសារនេះ នឹងផ្តល់ឱកាសឱ្យសហគមន៍ខ្មែរ ជួបជុំគ្នា ហើយបញ្ចេញយោបល់អំពីបញ្ហារបស់ខ្លួននោះ ថាជាអ្វី? តើអ្នកទាំងនោះបានចូលទៅប្រើធនធានដែលមានដាក់ឱ្យប្រើនោះ របៀបណា?

មានជូនភេសជ្ជៈនឹងអាហារថ្ងៃត្រង់ដោយសមាគម CFSA &MHASH

**ប្រធានបទ** ខួបឆ្នាំទី១ "សមាគមគាំទ្រគ្រួសារខ្មែរ" គម្រោងទៅអនាគត

**ទំនាក់ទំនង** រ៉េជី សំខុន ពិន ទូរស័ព្ទដៃ (215) 913-0083
ទូរស័ព្ទការិយាល័យ (267)507-3864

CFSA Committees: Ms.Sosimorn Chap, Mr.Mao Man, Ms. Soben Pin, Mr Mam Yin, Mr.Kim Phien, Mr. Hou teng, Mr. Vanthan Touch , Mr. Chhoeun Phal, Ms.Hiek Sreng, Ms.Khanho Lao, Mr.Channary Chea, Rith Sam Pen, Tray Holl,...

MENTAL HEALTH ASSOCIATION OF SOUTHEASTERN PENNSYLVANIA

The PEAK Program is a project of the Mental Health Association of SEPA



# ពេទ្យធ្មេញសំរាប់គ្រួសារ Caring Dental For ALL Ages




COMPLETE ផ្តល់គ្រប់សេវាកម្ម Services

- Cosmetic Dentistry
- Cosmetic Fillings
- Crowns & Bridges
- Dentures
- Extractions
- Implant Crowns
- Root Canal Therapy

- ត្រួតពិនិត្យទៀតទាត់ពេល
- សំអាតធ្មេញ
- ជំងឺចញ្ច្រាញធ្មេញ
- ដកសរសៃធ្មេញ
- ស្រោប-តម្រឹម និងប៉ះធ្មេញ
- ធ្វើធ្មេញឱ្យស
- បំពេញធ្មេញប្រហោង
- ដកធ្មេញ

Most Forms of Insurance & Payment
ACCEPTED ទទួលគ្រប់ អ៊ិនស្វ៊ិរន
MassHealth • Cigna • Aetna
Amex • Discover • Visa • Mastercard

Convenient LOCATION
Next to Bank of America on Chelmsford Street



FREE Teeth Whitening
New patients get a complimentary teeth whitening kit with completed exam, cleaning & x-rays at regular price. Cannot be combined with any other offers. Expires 30/04/2012

"EXCLUSIVE OFFER" $55.00
Limited Time New Patient Special
(Regular Discount $55.99 a $250 Value)
Present coupon for discount. Includes exam, bite-wing x-ray & cleaning. Cannot be combined with other offers or insurance. Expires 30/04/2012

យើងមានអ្នកនិយាយភាសាខ្មែរ អង់គ្លេស ស្ប៉ានីស និងវៀតណាម សូមទូរស័ព្ទ 978-455-4039 ដើម្បីណាត់ជួបនៅថ្ងៃនេះ

724 Chelmsford Street • Lowell, MA • 978-455-4039
www.BrightSmiles–Dental.com

# ហាងមាសខ្មែរអង្គរ

## Khmer-Angkor 金美成珠寶行 Jewelry

Since 1983
Certified Diamonds & Diamond Jewelry

**Father´s Day Sale**
up to 50% OFF
all in stock watches
លក់បញ្ចុះតម្លៃ ៥០% ក្នុងរដូវទិវាបិតា




18K & 24K Gold, Platinum Jewelry & Watches
GIA Graduate Gemologist on Staff
Authorized RADO & LONGINES Dealer Repairs Done on Premises

600 Washington Avenue. Unit 12B. Philadelphia, PA 19147
Tel. 215-599-2222 Fax. 215-599-2223

Open
Tuesday-Sunday
10:30AM-6:30PM
Closed Monday

# Mekong River

VIETNAMESE RESTAURANT

**1120-1124S Front St.,**
**Philadelphia, PA 19147**
(Near Washington Ave. - មានកន្លែងចតឡានត្រឹមត្រូវ
**215-467-6100**

# GRAND OPENING
# 25-5-2012

មានម្ហូបវៀតណាមគ្រប់មុខ

ហ្វឺ មី គុយទាវ នំបញ្ចុក បាញ់ហយ

បាយ ម្ហូបបួស ម្ហូបឆា ម្ហូប សម្រាប់ទទួលជាលក្ខណៈគ្រួសារ

ទទួលពិធីជប់លៀងជាលក្ខណៈគ្រួសារ ឬជួបជុំមិត្តភ័ក្រ

BYOB






**មានភោជនីយដ្ឋានទើបបើកនៅក្នុងសហគមន៍យើង**

ហាងមាសរស្មី
SUNSHINE JEWELRY, INC.
215-271-2950



Certified Diamonds & Golds (24K & 18K)
Men & Women Jewelries & Watches
Custom Design & Repairs on Premise
15 Years in Services & Growing Strong



702 Washington Ave. Phila., PA 19147
www.sunshinejewelryonline.com


# វិធីបំប៉នសរសៃសក់ឲ្យរស់រវើក



●នៅក្នុងផ្លែត្រសក់ គឺសម្បូរទៅដោយសារជាតិម៉យជីវ៉ៃសើរបែបធម្មជាតិ ចំណែកទឹកដោះគោជូរវិញ ជួយឱ្យសរសៃសក់មានទម្ងន់ រីឯទឹកឃ្មុំជួយឱ្យសរសៃសក់ឡើងខ្មៅរលើបរលោង ។

នៅក្នុងថ្ងៃឈប់សម្រាកបើអ្នកមិនចង់ចេញទៅក្រៅផ្ទះ ព្រោះចង់សន្សំប្រាក់នោះ យើងណែនាំ ដើម្បីថែបំប៉នឱ្យសក់ស្រស់ស្អាតដោយដៃខ្លួនឯង ដូចខាងក្រោមនេះ :

**គ្រឿងផ្សំ :**

- ផ្លែត្រសក់ហាន់ជាចំណិត១ផ្លែ
- ទឹកដោះជូររសជាតិធម្មជាតិ១កែវ
- ទឹកឃ្មុំ៣ស្លាបព្រាបាយ

**វិធីធ្វើ :**

១-ដាក់គ្រឿងផ្សំទាំងអស់ទៅក្នុងឧបករណ៍ក្រឡុករហូតដល់រលាយចូលសាច់តែមួយ ។

២-ប្រើល្បាយដែលក្រឡុកបាននេះ យកទៅលាបឱ្យសព្វតាំងពីគល់សក់រហូតដល់ចុងសក់ ។

៣-យកកន្សែងពោះគោជ្រលក់ទឹកក្តៅបន្តិច រួចពូតឱ្យនៅស្រពាប់ បន្ទាប់មកយកមកឃ្លុំលើក្បាលទុកចោលប្រមាណជា២០នាទី ។

៤-លាងទឹកចេញឱ្យស្អាតកក់សក់ធម្មតា ។

រូបមន្តដើម្បីឱ្យសក់ស្អាតនេះ ប្រសិនបើបានធ្វើក្នុងមួយសប្តាហ៍ម្តងអ្នកនឹងមានអារម្មណ៍ប្លែកប្រែប្រួល ពិសេសអ្នកដែលមានបញ្ហាសរសៃសក់ស្ងួត ហើយប្រយោជន៍ដែលទទួលបាន គឺធ្វើឱ្យសរសៃសក់មានភាពរស់រវើកដូចធម្មជាតិគួរឱ្យចង់អង្អែល ហើយស្បែកក្បាលត្រជាក់ស្រួលទៀតផង ។

នៅមានចំណុចពិសេសមួយទៀត គឺក្លិនដ៏ក្រអូបស្រទន់ពីផ្លែត្រសក់ជាប់នៅនឹងសរសៃសក់បានយូរថ្ងៃទៀតផង ៕


ឱសថស្ថាន TRX PHARMACY
5520 Whitaker Avenue Unit C (Next To BEN CITY)
PHILADELPHIA, PA 19124 TELEPHONE: 215-288-8701



ម្ចាស់ហាង: ស៊ីវ អេង

- យើងទទួលយកអ៊ិនស៊ូរិនស្ទើរតែទាំងអស់
- អាចយកថ្នាំទៅជូនដល់ផ្ទះ
- មានគម្រោងបង់ថ្លៃពិសេស សម្រាប់ "ខូប៉េយ"ដែលមានតម្លៃខ្ពស់
- ពិសេស: មានជូនកំរៃ៤៥សម្រាប់អ្នកមកទិញថ្មីដែលមានការផ្ទេរវេជ្ជបញ្ជា
- កន្លែងចតឡានធំទូលាយ
- សេវាត្រឹមត្រូវច្បាស់លាស់ មានវិជ្ជាជីវៈធ្វើការលឿន
- មានរង្វាន់ បើយកវេជ្ជបញ្ជាមកទិញថ្នាំ

**ពិសេស** : ជូនម្សៅអិនស្ទមួយកំប៉ុងពេលទិញតាមវេជ្ជបញ្ជា១០មុខ មានសំរាប់ភ្ញៀវដែលគ្មាន អិនស៊ូរិន មានថ្នាំជេណេរិតច្រើនរាយមុខតម្លៃ $14.99 សំរាប់៩០ថ្ងៃ ថ្នាំអនតាយបាយ៉ូទិក ដូចជា Amoxicillin, Ampicillin, Cephalesin តម្លៃ $4



រាល់ខែមានចាប់ឆ្នោតសម្រាប់អ្នកយកថ្នាំនៅទីនេះ អាចត្រូវឆ្នោតវត្ថុ ដូចជា
Ipod 3



គាំទ្រគ្រូពេទ្យប្រចាំគ្រួសាររមាន :

TRUONG NGUYEN, MD
5746 Rising Sun Avenue
Philadelphia, PA 19120
215-904-6891

KENNETH NGUYEN, MD
448 E WYOMING AVE
Philadelphia, PA 19120
215-324-2180

NICHOLAS TRUONG, MD
133 EAST LEHIGH AVE
Philadelphia, PA 19125
215-426-9344

# NEW CHINA PEARL

DIM SUM •RESTAURANT •BAR

ឌីមសាម ភោជនីយដ្ឋាន និងបា





មានឆាករាំសំរាប់ពិធីការ ឬប្រជុំកំសាន្ត
មានឌិនស៊ុមរាល់ថ្ងៃ

មានម្ហូបគ្រឿងសមុទ្រស្រស់រាល់ថ្ងៃ
សៀវភៅមុខម្ហូបយើងខ្ញុំមានរាប់រយមុខ ដូច China town
ដែលលោកអ្នកការកុម្មង់បានតាមតម្រូវការ

ភោជនីយដ្ឋាន "ញូឆាណាភើល" សូមអញ្ជើញលោកអ្នកនិងក្រុមគ្រួសារមករីករាយជាមួយម្ហូបអាហារមកពីហុងកុង និងប្រទេសអាស៊ីនានាជុំវិញ ។ យើងមានសាលរាំកំសាន្តសំរាប់ពិធីការ ឬរាត្រីជួបជុំគ្នា មានបា និងខារ៉ាអូខេ ទៀតផង ។ កន្លែងចតឡានមិនយកថ្លៃ ហើយមានសុវត្ថិភាពល្អ ។

**BUSINESS HOURS:** Mon - Wed 11 a.m. - 10 a.m./Thurs. & Fri. 11 a.m. - 12 Midnight / Sat. 10 a.m. - 12 Midnight
Sun.10 a.m. - 10 p.m. Delivery Hours 11 a.m. - 9 p.m. min. $15 order plus $2 delivery.

288 Mishawum Rd., Woburn, MA 01801 / Phone:(781) 932-0031/ www.NewChinaPearl.com
From Boston 95 South; Exit 37B, from Lowell / 93 South; Exist 37B, from RT-128; Exit 36.



# 華 China Star 星

ភោជនីយដ្ឋាន ឆាយណាស្តារ



មានម្ហូបចិន
ម្ហូបប៉ូលីណេស៊ី
ម្ហូបចិនកង់តុង
ម្ហូបម៉ង់ដារិន

Chinese -Polynesian -Cantonese -Mandarin
369 Broadway St., Lowell, MA 01854
Tel: 978-454-7578, 978-454-7507

**Open Daily: Sun. to Thurs. 11:00 AM to 1:00 AM**
**Fri. and Sat. 11:00 AM to 3:00 AM**



យើងអាចយកម្ហូបទៅដល់ផ្ទះបាន

We Deliver All Day: 11:30 AM to 1:00 AM Available to most areas. Min. $10.00 Delivery Charge $2

**$19.95**

បង្កងឆាខ្ទឹម និងខ្ញីពិសេស

SPECIAL 2 Lobsters w/ Scallion & Ginger



# វាគឺនៅទីនេះ

ផែនការសុខភាពដែលមនុស្សចាស់សមតែទទួលបាន។



**Senior Whole Health (SWH)**-គឺជាផែនការសុខភាពសំរាប់មនុស្សដែលមានអាយុ 65 ឬច្រើនជាងនេះនៅលើ **MassHealth Standard** ។

អត្ថប្រយោជន៍ និងសេវារបស់យើងខ្ញុំ ដែលមិនគិតថ្លៃចំពោះអ្នក រួមមាន :

- អត្ថប្រយោជន Medicare និង Medicaid benefits ទាំងអស់។
- ការរ៉ាប់រងឱសថតាមវេជ្ជបញ្ជា និងមិនមានវេជ្ជបញ្ជាពេញលេញ។
- ការថែទាំជើង វ៉ែនតា និងការថែទាំធ្មេញ។
- សមាជិកក្លឹបសុខភាព/កន្លែងហាត់ប្រាណ។
- ការដឹកជញ្ជូនសំរាប់ការណាត់ជួបព្យាបាល។

SWH SENIOR WHOLE HEALTH®

**1-888-566-3526 (Toll-free)**
**711 (TTY)**
**www.seniorwholehealth.com**

*Senior Whole Health* អាចមានប្រើប្រាស់ចំពោះជនដែលមានអាយុ 65 ឆ្នាំ ឬច្រើនជាងនេះ នៅលើ *MassHealth Standard* និងរស់នៅក្នុងខោនធី *Bristol, Essex, Middlesex, Norfolk, Plymouth, Suffolk* ឬ *Worcester County* ។

ព័ត៌មានអំពីអត្ថប្រយោជន៍ដែលផ្តល់ជូននៅក្នុងនេះ គឺជាសេចក្តីសង្ខេប តែមិនមែនជាសេចក្តីពណ៌នាពេញលេញអំពីអត្ថប្រយោជន៍ ដែលអាចមានប្រើប្រាស់ឡើយ។ ព័ត៌មានបន្ថែមអំពីអត្ថប្រយោជន៍ អាចមានប្រើប្រាស់ដើម្បីជួយអ្នកនៅក្នុងការធ្វើសេចក្តីសម្រេចអំពីការរ៉ាប់រងរបស់អ្នក។ នេះគឺជាការផ្សព្វផ្សាយ ពាណិជ្ជកម្ម។ សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់ផែនការ។ Senior Whole Health HMO គឺជា ផែនការសុខភាពស្ម័គ្រចិត្ត ដែលមានកិច្ចសន្យាជាមួយ Medicare និង MassHealth ។ H2224_2009_066 3/12/09


SIM'S
Major Sim Enterprises, Inc.
Home Improvement
ជាងសំណង់តាស៊ីម
License#CS 88569 Registration#153685
978-452-7467 / 978-421-3672 / 978-420-8551
FREE ESTIMATES
60 Middlesex St. (Rte.110) Lowell, MA 01852
FULLY INSURED
ជួសជុល កែលំអរ សង់បន្ថែម
Kitchen ចង្ក្រានបាយ
Livingroom បន្ទប់ទទួលភ្ញៀវ
Bathroom បន្ទប់ទឹក
Bedroom បន្ទប់ដេក
Roofing ដំបូល
Siding ជញ្ជាំង
Window បង្អួច
Door ទ្វារ
Basement ជាន់នៅក្រោមដី
Additions បន្ទប់បន្ថែម
Residential • Commercial • Industrial
ទទួលប្រាក់គ្រប់ប្រភេទ
Bank Loan, Insurance, Compensation, Credit Debit Card, Check &Cash
More information call: 1.978.452.7467
www.simshomeimprovement.com
Boreth@simshomeimprovement.com


Yoo's Auto Service and Collision
យូ បំរើសេវារថយន្ត
នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច
FREE ESTIMATES
យើងអាចជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក
ឱ្យបានប្រសើរបំផុត ដើម្បីសុវត្ថិភាពលោកអ្នក
មិនឱ្យខុសចិត្តឡើយ ។
ផ្នែកជាងម៉ាស៊ីន
ផ្នែកជួសជុលតួរថយន្ត
Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission
Inspection & Repairs
Muffler & More
Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists
Yoo's AUTO COLLISION
215-457-7777 • 215-457-7779
189 W. Duncannon Ave. Phila., PA 19120
ទូរស័ព្ទរក SAM 215-457-7777 ឬ
215-457-7779, Fax-215-457-7475


Phở Hà Saigon
Vietnamese Restaurant
7 days A Week
9am-9pm
B.Y.O.B.
ជាហាងដែលធ្វើ ហ្វឺ ឆ្ងាញ់ជាងគេនៅហ្វីឡាដែលហ្វៀ
ចុងភៅដែលពូកែធ្វើ ហ្វឺ និងម្ហូបផ្សេងៗឯទៀត
ត្រូវមាត់ភ្ញៀវគ្រប់ៗរូប ឥឡូវនេះមកធ្វើម្ហូបនៅហាងយើងខ្ញុំ
ហើយធានាថា ម្ហូបអាហារហាងPhở Hà Saigon
និងបំរើលោកអ្នកបានយ៉ាងពេញចិត្តគ្រប់ពេលវេលា
W Porter St
W Shunk St
Greenwich Recreation Center
Phở Hà Saigon
W. Oregon Ave
Toys R us
Schuylkill Expy
Delaware Expy
320 W. Oregon Avenue, Suite 1. Philadelphia, PA 19147
Tel: (215) 389-1002 (Inside Oregon Market)
VISA
MasterCard
DISCOVER NETWORK

# ប្រវត្តិរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ រ.ជ.រ.ប.ខ លោកតា សឺន សាន



ដោយ : ម៉ម យឹន

(តពីលេខមុន)

ដោយសារតែកិច្ចសន្យានេះហើយបានជា ចាប់តាំងពីឆ្នាំ១៩៩៣ គឺក្រោយថ្ងៃបោះឆ្នោតសកល ទោះបីពេលនោះមានជួបប្រទះបញ្ហាមិន ចុះសម្រុងគ្នានៅក្នុងភាគីបង្រួបបង្រួមគ្នានោះ យ៉ាងណាក៏ដោយ ក៏អង្គការសហប្រជាជាតិដែលទទួលបេសកម្មជាអ្នករៀបចំការបោះឆ្នោតសកលបានខិតខំពុះពារហូតបានសម្រេចចេញជាសន្តិភាពមួយដល់ប្រទេសខ្មែរ រហូតអង្គការសហប្រជាជាតិព្រមឱ្យមេដឹកនាំខ្មែរគ្រប់និន្នាការចូលរួមដោះស្រាយនូវគ្រប់បញ្ហាដោយខ្លួនឯង។ ទោះបីមានការខ្លះធ្វើពុំសមស្របតាមសន្ធិសញ្ញាអន្តរជាតិនៅក្រុងប៉ារីសនោះក៏ដោយ។

ដូច្នេះកិច្ចសន្យាដែលសន្ធិសញ្ញាអន្តរជាតិបានប្រគល់ឱ្យថា ត្រូវតែជួយកសាងស្ដាបនាប្រទេសខ្មែរឡើងវិញនោះ បានចាប់ផ្ដើមអនុវត្តន៍យ៉ាងសកម្មតាំងពីពេលនោះមកដែរ។

មុននឹងបន្តការជម្រាបជូនអំពីសកម្មភាពកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ ក.ជ.រ.ប.ខ សូមលើកយកការភ្ញាក់រឭកបញ្ញាវ័ន្ត និងសកម្មជនស្នេហាជាតិមួយចំនួន ដែលបានរស់រានមានជីវិតគង់នៅក្រោយពីបានរស់យ៉ាងមហាសែនវេទនាក្នុងសម័យក្រុមខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យនោះមក។ លុះមកដល់ឆ្នាំ១៩៧៩ ក៏បានជួបប្រទះនូវព្រឹត្តិការណ៍ថ្មីមួយទៀត ដែលមុនដំបូងនឹកស្មានថា ជាភព្វព្រេងវាសនាដ៏ល្អប្រសើររបស់ប្រទេស និងជនជាតិខ្មែរ ក្រោយពីបានឆ្លងកាត់មហារងទុក្ខមក ប៉ុន្តែក្រោយពីបានសង្កេតមើលឱ្យបានច្បាស់លាស់ ទើបបានឃើញ និងដឹងថាសកម្មភាពយ៉ាងតក្រឹកតគ្រេងនៃកងទ័ពយួនក្រហម បានចូលមកវាយប្រហារកងទ័ពក្រុមខ្មែរក្រហមមានចំនួនប្រមាណម្ភៃម៉ឺននាក់ (២00.000) និងអ្នកជំនាញការទីប្រឹក្សាជាច្រើនពាន់នាក់នេះ បានចូលមកនៅពាសពេញគ្រប់ច្រកល្ហកនៃប្រទេសខ្មែរទាំងមូល ។ ដែលជាហេតុធ្វើឱ្យសកម្មជនស្នេហាជាតិនឹកឃើញទៅដល់ប្រវត្តិសាស្ត្រខ្មែរបានចែងទុកមកអំពីមហិច្ឆិតាលោភលន់របស់ប្រទេសជិតខាង គឺយួន និងសៀម ។ ទើបបណ្ដាលឱ្យសកម្មជនយល់ឃើញថា កងទ័ពយួនក្រហមលើកទ័ពចូលមកនេះ ប្រាកដជាស្ថិតនៅក្នុងគម្រោងផែនការពង្រីកទឹកដីនោះហើយ ដូចប្រវត្តិសាស្ត្របានចែកទុកមកមែន។

ដោយយល់ឃើញដូច្នេះហើយ ទើបសម្រេចចិត្តរៀបចំផែនការប្រជុំសម្ងាត់ ដើម្បីជួបជុំបញ្ញាវ័ន្តមួយចំនួនទាំងចាស់ទាំងក្មេងក្នុងគោលបំណងរិះរកវិធីជួយទ្រទ្រង់ការពារប្រទេស និងជនជាតិខ្មែរ កុំឱ្យធ្លាក់ទៅក្នុងការត្រួតត្រារបស់ប្រទេស និងកងទ័ពយួនក្រហម និងជួយការពារឯករាជ្យភាព បូរណភាព និងអធិបតេយ្យភាពទឹកដីខ្មែរ ដែលជនជាតិខ្មែរទាំងប្រទេសបានក្រោកឡើងតស៊ូទាមទារ ពីអាណានិគមនិយមបារាំង ។ រួចហើយបានទទួលជោគជ័យបានឯករាជ្យពេញបរិបូរកាលពីថ្ងៃទី៩ខែវិច្ឆិកា ឆ្នាំ១៩៥៣ ហើយមានការធានារ៉ាប់រងពីសន្និសីទអន្តរជាតិ នាក្រុងហ្សឺណែវប្រទេសស្វីសនាឆ្នាំ១៩៥៤ ។

ការជួបជុំប្រជុំគ្នាសម្ងាត់នេះ ក្រោយពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់មក អង្គប្រជុំបានសម្រេចដាក់ឈ្មោះចលនានេះថា"ចលនាព្រលឹងខ្មែរ"ដោយមានគោលការណ៍ និងគោលបំណងជា ជនជាតិខ្មែរពេលនេះ ប្រៀបដូចជាមនុស្សម្នាក់ដែលកំពុងបាត់បង់អស់នូវព្រលឹងវិញ្ញាណ ធ្វើឱ្យមនុស្សនោះទៅជាវង្វេងវង្វាន់ បាត់សតិស្មារតី ប្រៀបដូចមនុស្សវិកលចរិត(ឆ្កួត)។ ដោយឃើញសភាពរបៀបនេះ ទើបបងប្អូនញាតិសណ្ដាន នាំគ្នាធ្វើពិធីមួយហៅថា ពិធីហៅអន្ទងប្រមែប្រមូលព្រលឹងមនុស្សនោះ ឱ្យវិលត្រឡប់ចូលមកក្នុងរូបអង្គរាងកាយរបស់មនុស្សនោះវិញ ។ ទើបមនុស្សនោះ នឹងបានមានសតិស្មារតីដឹងខ្លួន នឹងស្គាល់នូវអ្វីៗឡើងវិញ ហើយបានក្លាយទៅជាមនុស្សធម្មតាដូចគេដូចឯង។



ការធ្វើដូច្នេះ គឺជាទំនៀមទំលាប់ជនជាតិខ្មែរដែលមានតាំងពីយូរយាមកហើយ ពេលនេះទៀតសោតជនជាតិខ្មែរក៏កំពុងស្ថិតនៅក្នុងសភាពដូចគ្នា ពីព្រោះមានជនជាតិដទៃបានព្យាយាមធ្វើបាបជិះជាន់សង្កត់សង្កិនរហូតដល់សម្លាប់ជីវិតជនជាតិខ្មែរ ធ្វើឱ្យក្លាយទៅជាមនុស្សបាត់បង់សតិវិញ្ញាណសឹងតែអស់រលីង។

ការប្រជុំលួចលាក់ដោយសម្ងាត់នេះ បានធ្វើឡើងជាញឹកញាប់ ដោយមានប្រជាពលរដ្ឋខ្មែរជាច្រើនបានគាំទ្រ ។ ប៉ុន្តែទោះបីចលនានេះបានខិតខំលាក់កំបាំងដូចម្ដេចក៏ដោយ ក៏ពុំអាចគេចផុតពីអំណាចនៃកងទ័ពយួនក្រហមបានដែរ។

តទៅលេខក្រោយ


ANGKOR AUTO SERVICE,INC.

ហាងជួសជុលរថយន្ត "អង្គរ"

Free Estimate

Auto Body and Maintenance



BODY WORKS

Auto glass and windshields

Auto Frame Straightening and Painting

មានបទពិសោធន៏២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្ហូរិនបានផង យើងផ្ដល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES

State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425



ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

Rathe´s Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២00៨ ទៅ : - ដូរប្រេងក៏រិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្ដាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។

ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376




# ស្បែកស្អាតដោយមិនបាច់ចំណាយខ្ជះខ្ជាយ



•រូបមន្តសន្សំសំចៃថវិកាពេលនេះ ប្រាកដគេចមិនផុតពីការយកចិត្តទុកដាក់នៅលើស្បែកត្រង់ជើងនោះទេ ព្រោះចំណុចមួយនេះជាចំណែកមួយដែលមនុស្សភាគច្រើននាំគ្នាមើលរំលងក្នុងការថែរក្សា រហូតបណ្តែតបណ្តោយឱ្យក្រៀមស្ងួតប្រេះស្បែក ទើបប្រញាប់ប្រញាល់ងាកមកយកចិត្តទុកដាក់នៅពេលក្រោយ ។ ផលអាក្រក់វិញ គឺប្រសិនបើជើងរបស់អ្នកមិនទទួលបានការថែបំប៉នអស់រយៈពេលយូរឱកាសដែលអាចធ្វើឱ្យស្បែកត្រឡប់មកមានសភាពទន់ល្មើយបានដូច ដើមឡើងវិញនោះទាមទារឱ្យចំណាយពេលយូរ ។

វិធីណែនាំគឺតម្រូវឱ្យត្រៀមអង្ករអូដ១វែក សម្លជាមួយនឹងទឹកក្រូចឆ្មារមួយផ្លែចាក់លាយចូលគ្នាកូរឱ្យសព្វ រួចនាំយកទៅលាបបំពោកលើជើងចាប់ពីកជើងរហូតដល់បាតជើង ។ បន្ទាប់មកទៀតពុះក្រូចឆ្មារមួយចំហៀងផ្លែយកទៅត្រដុសត្រង់កែងជើងដែលជាស្បែកក្រិនដោយទុកចោលពី៥-១០នាទី ទើបប្រើទឹកក្តៅឧណ្ហៗលាងជម្រះ និងលាងម្តងទៀតដោយទឹកត្រជាក់ជូតឱ្យស្ងួត ។ ជាចុងក្រោយត្រូវលាបផលិតផលម៉យចឺរ៉ាយសឺដោយត្រូវលាបឱ្យច្រើននៅត្រង់ស្បែកក្បិន ។ ប្រសិនអាចធ្វើបានរាល់ថ្ងៃស្បែកដែលក្រិននឹងទន់ល្មើយឡើងវិញមិនខាន ៕

# របៀបសម្អាតប្រអប់ជើង និងក្រចក



•••មនុស្សភាគច្រើនតែងតែមើលរំលងចំពោះការថែទាំជើង ព្រោះយល់ថា ជើងគឺជាអវយវៈ មួយដែលមិនសូវមាននរណាចោលភ្នែកមើលប៉ុន្មានឡើយ ។ បើលោកអ្នកគិតយ៉ាងនេះ គឺមិនមែនជាការគិតត្រឹមត្រូវឡើយ ដូចនេះការដែលយើងមានជើង និងក្រចកជើងស្អាត ឬកែងជើងទន់ល្មើយនោះក៏វាប្រសើរជាងជើងដែលរឹងគគ្រាត និងកែងជើងស្ងួតប្រេះដែរ ។ ម្យ៉ាងទៀតការថែទាំជើងវាមិនមែនជាការពិបាក ឬត្រូវចំណាយពេលអ្វីយូរណាស់ណាទេ ។

ដូច្នេះសុភាពស្ត្រីទាំងឡាយគួរតែចំណាយពេលយ៉ាងហោចណាស់មួយសប្តាហ៍ម្តង ដើម្បីលើកសោភ័ណភាពជើងយើងមានដូចខាងក្រោមនេះ :

ពេលដែលយើងលាងថ្នាំក្រចកចេញហើយអ្នកអាចចាប់ផ្តើមខាត់ជើងរបស់អ្នកបាន ។ ត្រូវយកចានដែកដាក់ទឹកក្តៅឧណ្ហៗ រួចចាក់អំបិលចូលបន្តិចបន្ទាប់មកដាក់ជើងចូលក្នុងចានដែកត្រាំមួយស្របក់ ។ យកច្រាសសម្រាប់ខាត់ជើងមកខាត់ថ្នមៗឱ្យសព្វ ឬបើចង់ឱ្យវាប្រសើរជាងនេះទៀតនោះអាចយកស្ករ សពណ៌កន្លក់មួយស្លាបព្រាបាយ, ទឹកឃ្មុំបន្តិច និងទឹកក្រូចឆ្មារមួយស្លាបព្រាកាហ្វេមកកូរបញ្ចូលគ្នាឱ្យសព្វ រួចហើយយកមកខាត់ជើង ។ ធាតុផ្សំទាំងអស់នេះក្រៅពីធ្វើឱ្យជើងស្អាតអស់ជាតិកខ្វក់ហើយនោះ វាថែមទាំងធ្វើឱ្យកែងជើងរបស់អ្នកទន់ល្មើយ គួរឱ្យចង់ស្ទាបអង្អែលទៀតផង ។

### វិធីសំអាតមួយបែបទៀត

•ត្រូវត្រៀមទឹកក្តៅឧណ្ហៗលាយជាមួយនឹងប្រេងអូលីវ រួចហើយដាក់ជើងត្រាំឱ្យបានប្រហែលជា៥នាទី ។

•ពេលត្រាំ និងខាត់ជើងរួចហើយត្រូវយកកន្ត្រៃកាត់ក្រចកមកកាត់ និងយកដែកអង្រួសក្រចក មករួសក្រចកឱ្យវាកាន់តែស្អាតថែមទៀត ។

•ត្រូវយកឡេសម្រាប់លាបជំនួយក្រចកមកលាបស្រឡាបតាមក្រចកជើង រួចយកឡេលាបខ្លួនមកលាបស្រឡាបជើងឱ្យសព្វ ។

•បើអ្នកចង់លាបថ្នាំក្រចកទៀត អ្នកត្រូវលើកពេលមួយយប់សិន ដើម្បីឱ្យក្រចកបានដកដង្ហើមខ្លះស្អែកឡើងសឹមលាបទើបជាការប្រសើរ ។

•ក្រៅពីការសម្អាត និងរក្សាទៅតាមដំណាក់កាលដូចដែលបានរៀបរាប់មកខាងលើនេះ ហើយប្រសិនបើចង់ស្តារសភាពជើង និងកែង ជើងពីរឹងគគ្រាតមកជាទន់ល្មើយនោះ អ្នកត្រូវលាងជើងឱ្យស្អាតមុននឹងចូលដំណេករៀងរាល់យប់ រួចយកឡេលាបខ្លួនមកលាបស្រឡាបឱ្យសព្វលើជើង ជាពិសេសលាបត្រង់កែងជើងឱ្យបានច្រើនផង ។ ប៉ុណ្ណឹងមិនទាន់គ្រប់គ្រាន់នៅឡើយទេ គឺអ្នកត្រូវពាក់ស្រោមជើងដេកផង ធ្វើយ៉ាងនេះឱ្យបានញឹកញាប់ស្បែកប្រអប់ជើងរបស់អ្នកនឹងស្រស់ភ្លឺថ្លាមិនខាងឡើយ ៕


East Coast Center

for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com




ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន
អាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឲ្យធំ កែខ្ទង់ច្រមុះ
កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។
និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត

381 West Broadway South Boston, MA 02127
(617) 464 - 0001

MARCOTTE LAW FIRM

ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

•សេចក្តីអន្តរាយដល់បុគ្គល
•ពិការភាពដោយសន្តិសុខសង្គម
•បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
•ច្បាប់គ្រួសារ និងលែងប្តីប្រពន្ធ
•គ្រោះថ្នាក់ចរាចរណ៍
•គ្រោះថ្នាក់នៅការដ្ឋាន
•បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

•Personal Injury
•Disability
•Sex & Drug Crimes, OUI
•Family Law & Divorce
•Traffic Accidents
•Work Accidents

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ
មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ

(978) 458-1229

www.marcottelawfirm.com

# ៧ថ្ងៃនៅលើទឹកដីម៉ាឡេស៊ី













**តពីលេខមុន**

●●●អាចប្រៀបផ្ទឹមនឹងប្រជុំកោះនោះបានឡើយ ។ ឆ្នេរសមុទ្រដ៏ប្រណិតផ្តល់នូវពេលវេលាលំហែកាយដែលមានពន្លឺព្រះអាទិត្យពេញបរិបូរណ៍ ទឹកសមុទ្រថ្លាឈ្វេងដូចត្បូងមរកតនៅព័ទ្ធជុំវិញប្រជុំកោះដែលមានសភាពល្អឥតខ្ចោះសម្រាប់ភ្ញៀវទេសចរទាំងឡាយ ។ ក្នុងនោះជីវិតនៅក្នុងបាតសមុទ្រដ៏ល្អវិចិត្រនៃកោះឡាំងកាវី ក៏បានទទួលស្វាមន៍អ្នកដែលមានចំណាប់អារម្មណ៍នឹងការមុជទឹកលេងនៅបាតសមុទ្រដោយរីករាយ ។

ឡាំងកាវី ត្រូវបានប្រសិទ្ធនាមថា ជាឧទ្យានធម្មជាតិដែលបានចុះបញ្ជីបេតិកភណ្ឌពិភពលោកដោយអង្គការយូនីស្កូ រួចហើយថែមទៀតផង ។ ដោយសារមរតកភូមិសាស្ត្រដ៏ស្រស់ត្រកាលរបស់ខ្លួនដែលមានទេសភាពដ៏ទាក់ ទាញបំផុត, ជ្រលងភ្នំ, រូងភ្នំ, ថ្មដុះកណ្តាលសមុទ្រ.ថ្មកប់បាតសមុទ្រ ដែលមានសភាពថ្លា ដូចទឹកកក និងផូស៊ីលដ៏ច្រើនសន្ធឹកសន្ធាប់ទៀត ។ ដោយមានប្រវត្តិសាស្ត្រភូគព្ភសាស្ត្រដែលមានអាយុកាលជាង៥០០លានឆ្នាំមុននោះប្រជុំកោះនេះមានសណ្ឋានថ្មដ៏វិសេសលើសគេ? ដែលអារម្មណ៍ស្រមើស្រមៃ និងពង្វក់ចិត្តរកស្មានមិនត្រូវ ។ ជាមួយគ្នានោះនៅមានទីកន្លែងទាក់ទាញដ៏វិសេសលើសគេច្រើនទៀត សម្រាប់ស្វាគមន៍ភ្ញៀវទេសចរណ៍ដែលចូលចិត្តគយគន់ទេសភាពទៀតផង ។ ស្ពាមញ្ញញឹមដ៏ស្រទន់ និងបដិសណ្ឋារកិច្ចដ៏សែនកក់ក្តៅ និងក្លាយជាមន្តស្នេហ៍ដែលពួកគេមកសម្រាកលំហែកាយនៅកោះឡាំងកាវីមួយនេះ ។

នៅប្រជុំកោះឡាំងកាវីមានរមណីយដ្ឋានជាច្រើនកន្លែងផ្សេងៗទៀត ដូចជាចំណតដំបូងបំផុត នៅទីក្រុងគុអាស Kuah តំបន់ឆ្នេរខ្សាច់ធ្វើដំណើរកម្សាន្តតាមនាវា.ឆ្នេរតាំងជួរ Tanjuhg Rhu បឹងស្ត្រីក្រមុំមានផ្ទៃពោះ, ឧទ្យានធម្មជាតិដំបូងបង្អស់នៅអាស៊ីអាគ្នេយ៍.កសិដ្ឋានចិញ្ចឹមត្រីនៅបាតសមុទ្រ, អណ្តូងប្រាំពីរ ឬTelega Tujuh, ទឹកធ្លាក់ Durian Perangin មានកម្ពស់១៤ជាន់, រូងភ្នំGua Kelawar , រូងភ្នំGuapasir Dagang ។ វប្បធម៌ដែនកោះដ៏សម្បូរបែបមានសារមន្ទីរ និងមូលនិធិវប្បធម៌ Ibrahim Hussein សារមន្ទីរនេះមានសម្ងហកម្មគំនូររបស់លោក Datuk Ibrahim Hussein ដែលជាវិចិត្រករល្បីល្បាញមួយរូបរបស់ប្រទេសម៉ាឡេស៊ី, មានភូមិ អា-យើហានកាត Ayer Han Gat ដែលមានទីតាំងស្ថិតលើផ្ទៃដី១៦ហិកតា.ភូមិសិល្បៈជ្រលក់ល័ក្តអាត់មាអាឡាំ Atma Ala ដែលមានភូមិសិល្បៈដើមរបស់កោះឡាំងកាវីនៅក្នុង Padang Mat Sirat ដែលបង្ហាញអំពីសិល្បៈ និងវប្បធម៌របស់ប្រទេសម៉ាឡេស៊ី ។

សកម្មភាព និងទស្សនីយភាពផ្សេងទៀតនៅកោះឡាំងកាវី ដូចជាភូមិកែវចរណៃមានទីតាំងស្ថិតនៅ Jalanpantaicenang ដែលមានចម្ងាយពីអាកាសយានដ្ឋានឡាំងកាវី ប្រហែលជាង១០គីឡូម៉ែត្រ ។ ភូមិនេះផ្តល់នៅផលិតផលធ្វើអំពីកញ្ចក់ដែលគួរឱ្យទាក់ទាញ និងពោរពេញទៅដោយភាពឆើតឆាយជាច្រើនទៀត ។ ឡាម៉ានប៉ាឌី ឡាំងកាវី Laman Padi Langkawi ជាកន្លែងបង្ហាញអំពីប្រវត្តិសាស្ត្រកេរដំណែល និងការអភិវឌ្ឍន៍ការធ្វើស្រែដែលជាវិស័យកសិកម្មដ៏ចំណាស់បំផុតនៅម៉ាឡេស៊ី ។ ក្នុងចំណោមទីតាំងទាក់ទាញជាច្រើននៅទីនោះ គឺជាមន្ទីរស្រូវដែលដាក់បង្ហាញនូវវត្ថុបុរាណដ្យាក្រាម និងរូបថតដែលអធិប្បាយអំពីសារសំខាន់នៃការធ្វើស្រែក្នុងប្រទេស ។ KOTA MAHURI ជាផ្ទះរបស់នាងម៉ាស៊ូរីជារឿងអតីតកាលដែលទាក់ទងនឹងរឿងព្រេងនិទាន និងរឿងប្រវត្តិសាស្ត្រ គឺជាទីតាំងដ៏សំខាន់នៅលើកោះនេះ ។

ជាមួយគ្នានោះក៏មានការជិះទូកក្តោងនៅលើកោះឡាំងកាវី,រមណីយដ្ឋានរេបាក់ម៉ារីណា Rebak Marina, ឧទ្យានកំពង់ផែ Telaga ពិធីតាំងពិព័រណ៍នាវានិងយន្តហោះចំបាំងអន្តរជាតិ,ពិធីបុណ្យប្រណាំងទូកក្តោងធំៗអន្តរជាតិ,ពិធីប្រ-ណាំងទូកអន្តរជាតិ,ការប្រកួតកីឡាអន្តរជាតិឡាំងកាវី,ការប្រណាំងកង់ និងការដើរទិញទំនិញ និងទទួលអាហារនៅកោះឡាំងកាវី ៕ **ប៊ុនឡេង**



